# គម្រោងស្តីអំពី
# ការបន្ស៊ាំការកាត់បន្ថយនិងការគ្រប់គ្រងគ្រោះ
# មហន្តរាយពីការប្រែប្រួលអាកាសធាតុករណីសិក្សា
# តំបន់ឆ្នេរសមុទ្រខេត្តកោះកុង និងព្រះសីហនុ

- ធាតុអាកាស កំដៅ និងរបបទឹកភ្លៀងក្នុងប្រទេសកម្ពុជាគឺទទួលឥទ្ធិពលមូសុង ដោយបានបែងចែកជាពីររដូវកាលធំៗដូចជារដូវវស្សា (ចាប់ពីខែឧសភា ដល់តុលា)និងរដូវប្រាំង (ចាប់ពីខែ  វិច្ឆិកា ដល់មេសា)។
- ជាមធ្យមរដូវប្រាំងសីតុណ្ហភាពមិនលើសពី ៣២អង្សា
- ជាមធ្យមកម្រិតភ្លៀងធ្លាក់មានចន្លោះ ១,៤០០–២,០០០ មីលីម៉ែត្រ (mm) ដែលអត្រាភ្លៀងធ្លាក់ច្រើននៅតំបន់សមុទ្រ។



# ការប្រែប្រួលអាកាសធាតុនិងមុខសញ្ញាគ្រោះមហន្តរាយធម្មជាតិបង្កដោយការប្រែប្រួលអាកាសធាតុ







ប្រទេសកម្ពុជា គឺជាប្រទេសមួយងាយរងគ្រោះ ក្នុងចំណោមប្រទេសជាច្រើន ដែលមានភាពងាយរងគ្រោះជាមួយនឹងការប្រែប្រួលអាកាសធាតុ។ សីតុណ្ហភាពនៅប្រទេសកម្ពុជា អាចកើនរហូតដល់ 4°C




ផ្អែកតាមការសិក្សាគ្រោះរាំងស្ងួតបានបង្កផលប៉ះពាល់ដល់ប្រជាកសិករនៅក្នុងតំបន់ឆកសមុទ្រកំពង់សោម ដែលធ្វើឲ្យដូចខាតដំណាំកសិកម្ម។




បញ្ហានៃកង្វះទឹកប្រើប្រាស់ និងទឹកសម្រាប់វិស័យកសិកម្ម គឺជាកត្តាប្រឈមសំខាន់សម្រាប់ប្រជាកសិករ។

# ការកាត់បន្ថយផលប៉ះពាល់និងរបៀបបន្សុំនឹងការប្រែប្រួលអាកាសធាតុ



វិធីសាស្ត្រ ដើម្បីដោះស្រាយនឹងអាកាសធាតុដែលផ្លាស់ប្តូរលឿន យើងគួរផ្តល់មូលនិធិសម្រាប់វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះតាមរយៈកម្មវិធីវិនិយោគឃុំ/សង្កាត់ ដើម្បីធ្វើការសម្រេចនូវសកម្មភាពបន្សាំដែលប្រសើរជាងគេ។



ការប្រែប្រួលអាកាសធាតុធ្វើឱ្យធាតុអាកាសកាន់តែពិបាកក្នុងការព្យាករ ធ្វើឱ្យរដូវកាលដាំដំណាំប្រែប្រួល និងប៉ះពាល់ផលដំណាំរបស់យើង។ ការយល់ដឹងពីអាកាសធាតុធ្វើឱ្យយើងចេះជ្រើសរើសពេលវេលាសមស្របនិងចេះជ្រើសរើសប្រភេទដំណាំដែលធន់នឹងអាកាសធាតុ ដើម្បីបង្កើនទិន្នផល។



ការប្រែប្រួលអាកាសធាតុបង្កឱ្យមានគ្រោះរាំងស្ងួតកាន់តែញឹកញាប់។ តាមរយៈការជីកស្រះសហគមន៍យើងអាចមានទឹកប្រើប្រាស់សម្រាប់គ្រួសារ សត្វពាហនៈ និងដាំបន្លែ។



ការប្រែប្រួលអាកាសធាតុធ្វើឱ្យការស្វែងរកទឹកស្អាតកាន់តែលំបាក ជាពិសេសនៅក្នុងរដូវប្រាំងនិងពេលមានទឹកជំនន់។ តាមរយៈការប្រើប្រាស់ប្រព័ន្ធមួយចំនួនដូចជាពាងនីយូវី និងអូស្មូសុីស យើងអាចមានទឹកស្អាតប្រើប្រាស់ក្នុងតម្លៃទាបពេញមួយឆ្នាំ និងកាត់បន្ថយការប្រើអុស។



ដើម្បីកាត់បន្ថយហានិភ័យពីការប្រែប្រួលអាកាសធាតុ ប្រជាពលរដ្ឋមូលដ្ឋាន គប្បីអនុវត្តន៍កសិកម្មអភិរក្ស ដែលអាចជួយសម្រួល បង្កើនផលិតផលដំណាំ លើកកម្ពស់ជីវភាព និងសេដ្ឋកិច្ចគ្រួសារ។



បង្កើតប្រព័ន្ធក្នុងការស្តុកទឹកភ្លៀងទុក នៅរដូវវស្សា ដើម្បីប្រើប្រាស់នៅរដូវប្រាំង។



ស្តាប្រព័ន្ធស្រោចស្រប់ដែលមានស្រាប់តាមមូលដ្ឋាន ដើម្បីឲ្យប្រជាពលរដ្ឋអាចទាញយកទឹកប្រើប្រាស់សម្រាប់ដំណាំកសិកម្មបាន។




ចូលរួមចំណែកក្នុងការថែរក្សា ការពារ និងដាំព្រៃឈើឡើងវិញ ដើម្បីការពារភពផែនដី និងកាត់បន្ថយគ្រោះមហន្តរាយផ្សេងៗ។

# អ្នកអាចចូលរួមក្នុងសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ!

**គាំទ្រដោយៈ អង្គការមរតក**

Morodok អង្គការមរតក

ទូរសព្ទលេខៈ (៨៥៥)០៩៧ ៩១៩ ៦១៧២/០៩៣ ៣៥២ ៩៩៨
Email: oungtivea@gmail.com; Website: www.morodok.net
ការិយាល័យផ្ទះលេខៈ៤៣៧ ក្រុមទី៧ ស្រុក ស្រែអំបិល ខេត្ត កោះកុង